# អង្គការសង្គមស៊ីវិលថាតុលាការមានកំហុស បើកញ្ញា ឈឹម ស៊ីថរ ជាប់បម្រាមដូចការចោទប្រកាន់។




អង្គការសង្គមស៊ីវិលដែលធ្វើការលើវិស័យសិទ្ធិមនុស្សជាច្រើនស្ថាប័ន បដិសេធថា ប្រសិនបើតំណាងសហជីពកញ្ញា ឈឹម ស៊ីថរ មានជាប់បម្រាមរបស់តុលាការដូចការចោទប្រកាន់ នោះគឺជាកំហុសរបស់តុលាការទាំងស្រុង។

អង្គការក្រៅរដ្ឋាភិបាល និងសមាគមនានា ដូចជាសមាគមការពារសិទ្ធិមនុស្ស និងការអភិវឌ្ឍនៅកម្ពុជា (ADHOC) មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL) មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) និងអង្គការស្ថាប័នជាច្រើនផ្សេងទៀត បាននាំគ្នាធ្វើយុទ្ធនាការលើបណ្តាញសង្គមហ្វេសប៊ុកអំឡុងពេលដែលកញ្ញា ឈឹម ស៊ីថរ ត្រូវបានឃុំខ្លួនក្នុងពន្ធនាគារអស់រយៈពេល ៥សប្តាហ៍ ដោយទាមទារឱ្យរដ្ឋាភិបាលកម្ពុជាដោះលែងតំណាងសហជីពរូបនេះជាបន្ទាន់ និងដោយឥតលក្ខខណ្ឌ។

អង្គការសមាគមខាងលើអះអាងថា ការដាក់ទោសលើតំណាងសហជីពនៃក្រុមហ៊ុនណាហ្គាវើលដ៍ កញ្ញា ឈឹម ស៊ីថរ ដោយសារមិនបានអនុវត្តនូវលក្ខខណ្ឌដែលអាជ្ញាធរមិនដែលបានប្រាប់ឲ្យដឹងជាមុន គឺជាភាពអយុត្តិធម៌ និងជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើក្រមនីតិវិធីព្រហ្មទណ្ឌនៃប្រទេសកម្ពុជា។

ការអះអាងនេះ ធ្វើឡើងដើម្បីទាមទារឱ្យតុលាការដោះលែងមេដឹកនាំសហជីព កញ្ញា ឈឹម ស៊ីថរ ដែលត្រូវបានសមត្ថកិច្ចចាប់ឃុំខ្លួនជាលើកទី២ កាលពីពេលថ្មីៗនេះ។

កាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ សាលាដំបូងរាជធានីភ្នំពេញបានចេញសេចក្តីបំភ្លឺថា ការចាប់ឃុំខ្លួនកញ្ញា ឈឹម ស៊ីថរ កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២២ កន្លងទៅ គឺដោយសារតែជនត្រូវចោទបានចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ ដែលអំពើនេះគឺបានបំពានលើកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ អំឡុងពេលខ្លួនកំពុងត្រូវបានដាក់ឱ្យស្ថិតនៅក្រៅឃុំបណ្តោះអាសន្ន។

អ្នកគ្រប់គ្រងសិទ្ធិការងារនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស លោក យុន ថារ៉ូ ប្រាប់សារព័ត៌មាន The Cambodia Daily នៅថ្ងៃទី២ ខែមករា ឆ្នាំ២០២៣ នេះថា ប្រសិនបើតុលាការឯករាជ្យ សុក្រឹត យុត្តិធម៌ កញ្ញា ឈឹម ស៊ីថរ គួរតែត្រូវបានលើកកម្ពស់ និងការពារដោយច្បាប់ពីការខិតខំប្រឹងប្រែងរបស់ខ្លួនជុំវិញការចូលរួមការពារសិទ្ធិកម្មករ ដែលត្រូវបានក្រុមហ៊ុនរំលោភបំពានសិទ្ធិការងារលើកម្មករនិយោជិតដទៃទៀតរហូតមក។

លោក យុន ថារ៉ូ លើកឡើងថា ការចាប់ខ្លួនសកម្មជនសិទ្ធិការងារដ៏លេចធ្លោរូបនេះគឺជាការរំលោភលើសិទ្ធិមនុស្ស និងសិទ្ធិការងារយ៉ាងធ្ងន់ធ្ងរ ត្បិតការចោទប្រកាន់របស់តុលាការលើកញ្ញា ឈឹម ស៊ីថរ មិនបានផ្អែកលើមូលដ្ឋានច្បាប់នោះឡើយ។

លោកបន្ថែមថា កញ្ញា ឈឹម ស៊ីថរ គ្រាន់តែប្រើប្រាស់សិទ្ធិជាមូលដ្ឋានដែលមានចែងនៅក្នុងអនុសញ្ញាស្នូលរបស់អង្គការអាយឡូ ច្បាប់ស្ដីពីការងារ និងច្បាប់ស្ដីពីសហជីព ជាដើម ក្នុងការការពារសិទ្ធិ និងផលប្រយោជន៍ជាសមូហភាពរបស់សមាជិកសហជីព និងនិយោជិតកម្មករតែប៉ុណ្ណោះ។

មន្ត្រីអង្គការក្រៅរដ្ឋាភិបាលរូបនេះ ជំរុញឱ្យតុលាការធ្វើការពិចារណាឡើងវិញក្នុងការពិនិត្យមើលសំណុំរឿងកញ្ញា ឈឹម ស៊ីថរ និងទម្លាក់ចោលបទចោទប្រកាន់លើមេដឹកនាំសហជីពរូបនេះ ព្រមទាំងសកម្មជនសហជីពដទៃទៀតដែលកំពុងទទួលរងនូវការចោទប្រកាន់ពីតុលាការទាំងអយុត្តិធម៌នៅពេលនេះ។

គិតត្រឹមថ្ងៃទី២ ខែមករា ឆ្នាំ២០២២ នេះ កញ្ញា ឈឹម ស៊ីថរ ត្រូវបានតុលាការឃុំខ្លួនជាលើកទី២ ចំនួន ៣៧ថ្ងៃហើយ បើគិតចាប់តាំងពីថ្ងៃដែលសមត្ថកិច្ចបានចាប់ខ្លួនតំណាងសហជីពរូបនេះកាលពីចុងខែវិច្ឆិកា ឆ្នាំ២០២២ មក ខណៈសំណើសុំនៅ

ក្រៅឃុំបណ្ដោះអាសន្នពីមេធាវីរបស់កញ្ញា ឈឹម ស៊ីថរ ត្រូវបានតុលាការច្រានចោលទាំងស្រុងកាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២ កន្លងទៅ។

ជុំវិញការចាប់ខ្លួនតំណាងសហជីពរូបនេះ សហរដ្ឋអាមេរិក អូស្ត្រាលី និងអង្គការសង្គមស៊ីវិលជាច្រើន ចាត់ទុកការដាក់ទោសលើកញ្ញា ឈឹម ស៊ីថរ ដោយសារការខកខានក្នុងការអនុវត្តនូវលក្ខខណ្ឌដែលមិនបានប្រាប់ឲ្យដឹងមុនពីសំណាក់អាជ្ញាធរ គឺជាភាពអយុត្តិធម៌ និងល្មើសទៅនឹងគោលការណ៍ជាមូលដ្ឋាននៃនីតិរដ្ឋយ៉ាងធ្ងន់ធ្ងរ៕